# អង្គការ អាយស៊ីស៊ី
# គោលនយោបាយការការពារកុមារ

## ១. ប្រវត្តិឯកសារ

| អ្នកនិពន្ធ | កាលបរិច្ឆេទ | មូលហេតុនៃការផ្លាស់ប្តូរ | ជំនាន់ | លក្ខណៈ |
|---|---|---|---|---|
| អ្នកស្រី ធិន សារ៉ា | ២០០៣ | ការតាក់តែងឯកសារ | | ពង្រាង |
| អ្នកស្រី ធិន សារ៉ា | ២០០៤ | ការពិភាក្សានៅកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | | អនុម័ត |
| អ្នកស្រី ធិន សារ៉ា | ២០០៧ | ត្រួតពិនិត្យឡើងវិញ | | ពង្រាង |
| អ្នកស្រី ធិន សារ៉ា<br>លោក ជុំ ចាន់ដារិន<br>កញ្ញា ហ្វីនីវីឌសន់ ម៉ារៀ | ២០១០ | ត្រួតពិនិត្យឡើងវិញ | | ពង្រាង |
| អ្នកស្រី ធិន សារ៉ា<br>លោក ជុំ ចាន់ដារិន<br>កញ្ញា ហ្វីនីវីឌសន់ ម៉ារៀ | ២០១១ | ក្រុមប្រតិបត្តិ | ១.០០ | អនុម័ត |
| លោក ឆេង រ័ត្នជី<br>កញ្ញា ម៉េត ស្រីរ័ត្ន<br>លោក សាន ប៊ុនធឿន<br>លោក ស៊ុំ សុខុម<br>អ្នកស្រី សួន សោភា | ២០១៤ | ត្រួតពិនិត្យឡើងវិញ | | ពង្រាង |
| ក្រុមប្រតិបត្តិ | ១០ វិច្ឆិកា ២០១៤ | ត្រួតពិនិត្យឡើងវិញ និង ការធ្វើបច្ចុប្បន្នភាព | ២.០០ | អនុម័ត |
| លោក សេក ចាន់បូរ៉ា<br>កញ្ញា ស៊ីណា<br>លោក គិត សំណាង<br>លោក សាន ប៊ុនធឿន<br>លោក ស៊ុំ សុខុម | ២០១៩ | ត្រួតពិនិត្យឡើងវិញ<br>- សិក្សាស្រាវជ្រាវ អំពីស្តង់ដាអប្បបរិមាម្ចាស់ជំនួយ ច្បាប់កម្ពុជា ការតម្រូវខាងក្នុង (កុម្ភៈ -មេសា ២០១៩)<br>- ប្រមូលទិន្នន័យ ពីបុគ្គលិកអាយស៊ីស៊ី ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពគោលនយោបាយអាយស៊ីស៊ី (ឧសភា ២០១៩)<br>- ប្រមូលទិន្នន័យ ពីសហគមន៍គោលដៅ និង កុមារក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពគោលនយោបាយអាយស៊ីស៊ី (ឧសភា ២០១៩)<br>- វិភាគ និង ធ្វើបច្ចុប្បន្នភាព គោលនយោបាយការពារកុមារអាយស៊ីស៊ី (មិថុនា ២០១៩) | | ពង្រាង |
| ក្រុមប្រតិបត្តិ | ២២ មិថុនា ២០១៩ | គោលនយោបាយ និង ឧបសម្ព័ន្ធ ត្រូវបានត្រួតពិនិត្យ | ៣.០០ | អនុម័ត |

## ២. សេចក្តីផ្តើម

អង្គការអោយស៊ីស៊ី គឺជាអង្គការអភិវឌ្ឍន៍គ្រិស្តបរិស័ទគំនិតថ្មី ប្តេជ្ញាចិត្តក្នុងការបម្រើដល់អ្នកដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច ក្នុងព្រះរាជាណាចក្រកម្ពុជា។

អង្គការអោយស៊ីស៊ី ជឿថាយើងត្រូវក្លាយជាសម្លេងសម្រាប់កុមារ ដែលមិនអាចសម្តែងមតិសម្រាប់ខ្លួនឯងបាន។ កុមារជាច្រើននៅក្នុងប្រទេសកម្ពុជា កំពុងរងគ្រោះពីការរំលោភបំពានតាមទម្រង់ផ្សេងៗ (ឧទាហរណ៍ ការរំលោភបំពានផ្នែកសតិអារម្មណ៍ ការព្រងើយកន្តើយ ការរំលោភបំពានលើរាងកាយ ការរំលោភបំពានផ្លូវចិត្ត និង ការរំលោភបំពានផ្លូវភេទ។ល។) ហើយកុមារជាច្រើនកំពុងប្រឈមមុខនឹងភាពងាយរងគ្រោះ និងអំពើធ្វើអាជីវកម្ម ។ អង្គការអោយស៊ីស៊ី ប្តេជ្ញាចិត្តក្នុងការទប់ស្កាត់ ការពារកុមារ និងប្រព្រឹត្តចំពោះពួកគេដោយការគោរព និងជឿថាកុមារទាំងអស់ត្រូវបានបង្កើតមកជាតំណាងរបស់ព្រះជាម្ចាស់ដែរ។ (លោកុប្បត្តិ ១:២៧)

ការការពារកុមារ ជាប្រធានបទមួយក្នុងចំណោមប្រធានបទចំនួនបួនចេញពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដែលចូលជាធរមានក្នុងខែកញ្ញាឆ្នាំ១៩៩០ បន្ទាប់ពីទទួលបានការផ្តល់សច្ចាប័នពីប្រទេសមួយចំនួនធំ។ មកដល់បច្ចុប្បន្ននេះ មានប្រទេសចំនួន១៩៦ហើយ ដែលបានផ្តល់សច្ចាប័ន និងបញ្ចូលអនុញ្ញានេះចូលក្នុងច្បាប់របស់ខ្លួន[1]។

សិទ្ធិទាំងអស់ដែលមានចែងនៅក្នុងអនុសញ្ញា ត្រូវយកមកអនុវត្តចំពោះកុមារគ្រប់រូបដោយមិនប្រកាន់អំបូរ និងជាតិសាសន៍។ ទស្សនៈជាមូលដ្ឋានខាងក្រោយអនុសញ្ញាគឺថា កុមារមានតម្លៃដូចនឹងមនុស្សពេញវ័យនិងភាពស្មើគ្នា។ ប្រធានបទទាំងបួន ដែលកំណត់ជាគោលការណ៍ទូទៅរបស់អនុសញ្ញារួមមាន៖

- ការការពារ
- ការរស់រានមានជីវិត
- ការអភិវឌ្ឍ
- ការចូលរួម

កម្ពុជា គឺជាប្រទេសហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ អង្គការអោយស៊ីស៊ីធ្វើការនៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះយើងត្រូវតែមានតួនាទីជួយគាំទ្រលើកកម្ពស់ និងអនុវត្តអនុសញ្ញានេះក្នុងអង្គការអោយស៊ីស៊ី និងក្នុងគ្រប់គម្រោងកម្មវិធីទាំងអស់របស់យើង។

### ២.១ គោលបំណងនៃគោលនយោបាយ

គោលនយោបាយការការពារកុមារ ជាជំហានមួយឆ្ពោះទៅរកការកាត់បន្ថយការរំលោភបំពាន និងអំពើធ្វើអាជីវកម្មលើកុមារ នៅក្នុងប្រទេសកម្ពុជា។ គោលនយោបាយ អនុវត្តចំពោះជនទាំងឡាយណាដែលធ្វើការជាមួយ ឬពាក់

[1] https://treaties.un.org/Pages/ViewDetails.aspx?src=IND&mtdsg_no=IV-11&chapter=4&lang=en

ព័ន្ធនឹងអង្គការអាយស៊ីស៊ី និងគ្រប់គម្រោងកម្មវិធីទាំងអស់។ គោលនយោបាយនេះ គ្របដណ្តប់លើបុគ្គលិកជាតិ បុគ្គលិកបរទេស អ្នកស្ម័គ្រចិត្ត ភ្ញៀវ និងអ្នកជាប់កិច្ចសន្យាទាំងអស់ (ពីនេះតទៅហៅថា បុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី)។ គោលនយោបាយនេះ ពិពណ៌នាយ៉ាងច្បាស់លាស់ អំពីការរំពឹងទុកនៃអាកប្បកិរិយា និងក្រមសីលធម៌ នៅពេលធ្វើការជាមួយកុមារ ក៏ដូចជាបង្ហាញឱ្យដឹងពីកិច្ចការដែលគួរធ្វើ ប្រសិនបើពួកគាត់មានកង្វល់ចំពោះកុមារ ឬសង្ស័យថាកុមារកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ដោយកត្តាណាមួយ។ គោលនយោបាយនេះ ត្រូវបានបង្កើតឡើង ដើម្បីៈ

- ទប់ស្កាត់ និងការពារកុមារពីការរំលោភបំពាន និង អំពើធ្វើអាជីវកម្ម
- ទប់ស្កាត់ និងការពារបុគ្គលិកអាយស៊ីស៊ី/ភាគីពាក់ព័ន្ធពីការចោទប្រកាន់មិនពិត និង ការចោទប្រកាន់គ្មានភស្តុតាង
- ទប់ស្កាត់ និងការពារឈ្មោះ និងកិត្តិសព្ទ ក្នុងនាមជាអង្គការ

### ២.២ វិសាលភាព

គោលនយោបាយការការពារកុមារ អនុវត្តចំពោះជនទាំងឡាយណាដែលធ្វើការជាមួយ ឬពាក់ព័ន្ធនឹងអង្គការអាយស៊ីស៊ី និងគ្រប់គម្រោងកម្មវិធីទាំងអស់។ គោលនយោបាយនេះ គ្របដណ្តប់លើបុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី ក្នុងកំឡុងពេលធ្វើការ និងតំណាងអង្គការអាយស៊ីស៊ី។

## ៣. ចំណុចបញ្ហាគោលនយោបាយ

### ៣.១ សេចក្តីថ្លែងការអំពីការប្តេជ្ញាចិត្ត

៣.១.១ អង្គការអាយស៊ីស៊ី ប្រកាន់ជំហរមិនមានការលើកលែងរាល់ទម្រង់នៃការរំលោភបំពាន និងអំពើធ្វើអាជីវម្មលើកុមារក្រោមអាយុ១៨ឆ្នាំ។

៣.១.២ នាយកប្រតិបត្តិ នឹងចាត់តាំងឱ្យមានមនុស្សពីរនាក់ទទួលបន្ទុកដោះស្រាយបញ្ហាការការពារកុមារ នៅក្នុងអង្គការ។

៣.១.៣ អង្គការអាយស៊ីស៊ី ប្តេជ្ញាចិត្តគាំទ្រច្បាប់ស្តីពីសិទ្ធិកុមារ និងសុខមាលភាពកុមារ។ នេះរួមមានៈ

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកមារ ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ ១៩៩២
- អនុសញ្ញា ស្តីពីអាយុអប្បបរមាកុមារធ្វើការ អនុក្រិតលេខ១៣៨ ឆ្នាំ១៩៩៩
- សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលពិភពលោកស្តីអំពីកុមារនៅទីក្រុងស្តុកខម ឆ្នាំ១៩៩៦ និងសមាជពិភពលោកក្នុងការតាមដានវាយតម្លៃនៅប្រទេសជប៉ុន ឆ្នាំ២០០១ ដែលជម្រុញឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បាទាប្រទេសកម្ពុជា ដាក់ចេញនូវផែនការរយៈពេល ៥ឆ្នាំ ប្រឆាំងការជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើកុមារឆ្នាំ២០០០-២០០៤
- រដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ស្តីពីការងារ

- ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការពន្យល់ ឆ្នាំ២០០៨
- គោលនយោបាយ ស្តីពីការថែទាំជំនួសសម្រាប់កុមារ ឆ្នាំ២០០៦
- ច្បាប់ ស្តីពីការការពារ និង លើកកម្ពស់សិទ្ធិជនមានពិការភាព ឆ្នាំ២០០៩
- ច្បាប់ ស្តីពីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង ការការពារជនរងគ្រោះ ឆ្នាំ២០០៥
- ច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
- ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨។

៣.១.៤ អង្គការអាយស៊ីស៊ី ជឿជាក់ថាកុមារទាំងអស់ក្នុងប្រទេសកម្ពុជា មានសិទ្ធិទទួលបានការទប់ស្កាត់ និងការការពារឱ្យជៀសផុតពីការរំលោភបំពាន ដោយមិនប្រកាន់ជាតិសាសន៍ សាវតាសង្គម អាយុ ភេទ ពណ៌សម្បុរ ពិការភាព សាសនា ឬជំនឿឡើយ។

៣.១.៥ អង្គការអាយស៊ីស៊ី ជឿជាក់ថាការរំលោភបំពាន និង អំពើធ្វើអាជីវកម្មលើកុមារ ជាទង្វើខុសឆ្គង។ ការនៅស្ងៀមស្ងាត់មិនអើពើ ក៏ជាទង្វើខុសឆ្គងដែរ។

៣.១.៦ អង្គការអាយស៊ីស៊ី ជឿជាក់ថាកុមារមានសិទ្ធិក្នុងការនិយាយ និង ត្រូវបានគេស្តាប់ខ្លួន ម្ល៉ោះហើយកុមារ ក៏នឹងត្រូវបញ្ចូលជាភាគីពាក់ព័ន្ធផងដែរ តាមដែលអាចធ្វើទៅបាន។

### ៣.២ និយមន័យការរំលោភបំពានលើកុមារ

ការរំលោភបំពានលើកុមារ គឺជារបួសផ្នែករូបរាងកាយដែលមិនមែនជាឧបទ្ទវហេតុ ឬអំពើមិនគួរគប្បីដែលកើតចេញពីការប្រព្រឹត្ត ឬខ្វះការយកចិត្តទុកដាក់ពីសំណាក់ឪពុកម្តាយ អ្នកមើលថែ បុគ្គលិកអាយស៊ីស៊ី និងមនុស្សជុំវិញកុមារ។ ការរំលោភបំពាន មានបន្ថែមដូចខាងក្រោមនេះ៖

៣.២.១ **ការរំលោភបំពានលើរាងកាយ៖** ជាទង្វើទាំងឡាយណាដែលធ្វើឱ្យកុមារមានរបួសជាក់ស្តែង ឬ ទំនងអាចនឹងមានរបួស ឬ ជាការខកខានមិនបានជួយទប់ស្កាត់ដែលបណ្តាលឱ្យមានរបួសលើរូបកាយ ឬការឈឺចាប់ដល់កុមារ ក្នុងនោះមានដូចជា វាយតប់ ទះ អង្រួន គ្រវីបោះបោក ធ្វើឱ្យរលាក ធ្វើឱ្យលង់ទឹក ធ្វើឱ្យថប់ដង្ហើម ឬ ធ្វើឱ្យកុមារពុល ដោយចេតនា។

៣.២.២ **ការរំលោភបំពានលើផ្លូវភេទ៖** ជាអំពើជាក់ស្តែងឬទំនងជាអំពើធ្វើអាជីវកម្មលើកុមារ ឬមនុស្សវ័យជំទង់ក្នុងសកម្មភាពផ្លូវភេទ ដែលពួកគេយល់មិនច្បាស់ ពួកគេមិនបានផ្តល់ការយល់ព្រម ឬជាអំពើរំលោភច្បាប់សង្គមហាមប្រាមឬក្រុមគ្រួសារ។ ក្នុងនោះ រួមមានដូចជាការប៉ះប្រដាប់ភេទកុមារ បង្ខំកុមារឱ្យមើលរូបអាសអាភាស ឬ រួមភេទ។

៣.២.៣ **ការរំលោភបំពានលើអារម្មណ៍/គំនិតប្រាជ្ញា៖** សំដៅលើសកម្មភាពដែលជាពាក្យសំដី ឬសញ្ញាមិនសមរម្យចំពោះកុមារ ឬការខកខានរយៈពេលយូរណាមួយក្នុងការផ្តល់ឱ្យកុមារនូវការថែរក្សាគ្រប់គ្រាន់ មិន

មែនរាងកាយនិងអារម្មណ៍។ សកម្មភាពបែបនេះ អាចពាក់ព័ន្ធនឹងការបង្ហាញដល់កុមារថាពួកគេគ្មានតម្លៃ មិនគួរឱ្យស្រឡាញ់ ឬមិនទាន់ល្អគ្រប់គ្រាន់ និងធ្វើឱ្យកុមារមានអារម្មណ៍ភ័យខ្លាច និងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់និងខូចខាត។

៣.២.៤ **ការព្រងើយកន្តើយ៖** ការបន្តឬការធ្វេសប្រហែសចំពោះកុមារ ឬការខកខានក្នុងការទប់ស្កាត់ឬការពារកុមារពីគ្រោះថ្នាក់ណាមួយដែលអាចបណ្តាល់ឱ្យមានគ្រោះថ្នាក់ដល់កុមារ (រាងកាយ អារម្មណ៍ និងសុខុមាលភាព)។ នេះរួមមានទុកឱ្យកុមារនៅរងារ ក្តៅ និង អត់ឃ្លាន ឬក៏ខកខានដោយមិនបានយកចិត្តទុកដាក់ក្នុងការថែរក្សា (ឧទា. ចំណីអាហារ សម្លៀកបំពាក់ ទីជម្រក ការអប់រំ ក្តីស្រឡាញ់) ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់កុមារ។

៣.២.៥ **ការរំលោភបំពានខាងព្រលឹងវិញ្ញាណ៖** ការរំលោភបំពានខាងវិញ្ញាណ កើតឡើងនៅពេលអ្នកដឹកនាំខាងវិញ្ញាណ ឬនរណាម្នាក់ក្នុងតំណែងមានអំណាច ឬសិទ្ធិខាងវិញ្ញាណ (នេះអាចមានដូចជា អង្គការស្ថាប័ន វត្ត ក្រុមជំនុំ ឬគ្រួសារ) ដែលប្រើអំណាច ឬសិទ្ធិក្នុងរបៀបខុសលើអ្នកដែល ទុកចិត្តដល់ពួកគេ ដោយមានចេតនាចង់គ្រប់គ្រង បង្ខិតបង្ខំ បោកបញ្ឆោត ឬគាបសង្កត់លើកុមារ។ ការរំលោភបំពានខាងវិញ្ញាណ ជាការប្រើអំណាចខុសក្នុងក្របខណ្ឌជំនឿ ដើម្បីបំពេញតម្រូវការរបស់អ្នករំលោភបំពាន (ឬបង្កើនឋានៈរបស់ខ្លួន) ដោយប្រើប្រាស់កុមារ។ ការរំលោភបំពានខាងវិញ្ញាណ បណ្តាលឱ្យមានគ្រោះថ្នាក់ខាងវិញ្ញាណដល់កុមារ និងអាចរាលដាលឱ្យមានការរំលោភបំពានជាទម្រង់ផ្សេងៗទៀត ដូចជា លើរូបកាយ អារម្មណ៍ និង ផ្លូវភេទ។

### ៣.៣ ក្រមអាកប្បកិរិយា

៣.៣.១ អង្គការអាយស៊ីស៊ី រំពឹងថាបុគ្គលិកទាំងអស់៖

- ផ្តល់ការគោរព និងសេចក្តីថ្លៃថ្នូរដល់កុមារទាំងអស់ដែលពាក់ព័ន្ធនឹងការងារអង្គការអាយស៊ីស៊ី។
- ត្រូវតែចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ដែលចែងថា ពួកគាត់បានអានគោលនយោបាយនេះ នឹងយល់ព្រមអនុវត្តតាម និងដឹងពីចំណាត់ការ ក្នុងករណីមានអាកប្បកិរិយាមិនគួរគប្បីណាមួយកើតឡើង (សូមមើល ៣.៣.៤)។
- អាចធ្វើការនៅតំបន់គោលដៅគម្រោងបាន បន្ទាប់ពីពួកគាត់ចុះហត្ថលេខាលើគោលនយោបាយការការពារកុមារអាយស៊ីស៊ី។
- នឹងអនុវត្តតាមក្រមប្រតិបត្តិល្អ។ **(សូមមើលឧបសម្ព័ន្ធទី ១)**
- នឹងមិនប៉ះពាល់កុមារ តាមរបៀបណាមួយដែលផ្ទុយនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- នឹងមិនដាក់វិន័យកុមារ តាមរបៀបណាមួយដែលផ្ទុយនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- នឹងមិនធ្វើអាជីវកម្មលើកុមារ តាមរបៀបណាមួយឡើយ។
- នឹងខិតខំធ្វើយ៉ាងណា ជៀសវាងធ្វើដំណើរ ឬនៅជាមួយកុមារមួយទល់នឹងមួយ (ឧ. កុមារម្នាក់នៅជាមួយបុគ្គលិកអាយស៊ីស៊ីម្នាក់ឯង)។

- នឹងមិនចូលក្នុងផ្ទះ ខណៈដែលកុមារនៅផ្ទះម្នាក់ឯង ពេលចុះទៅក្រុមគ្រួសារនៅផ្ទះ។

៣.៣.២ ភ្ញៀវទាំងអស់ នឹងត្រូវណែនាំឱ្យបានយល់ដឹងពីគោលនយោបាយការការពារកុមារអាយស៊ីស៊ី។ ភ្ញៀវដែលចុះតាមតំបន់គោលដៅគម្រោងអាយស៊ីស៊ី នឹងមិនត្រូវទុកចោលដោយគ្មានការណែនាំក្នុងម៉ោងការងារឡើយ ហើយភ្ញៀវនឹងចុះហត្ថលេខា និងអនុវត្តតាមគោលការណ៍ណែនាំក្រមអាកប្បកិរិយាសម្រាប់ភ្ញៀវ។ (**សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធ ៤**)

៣.៣.៣ មនុស្សពេញវ័យ នឹងតែងតែទទួលខុសត្រូវលើការប្រព្រឹត្តរបស់ខ្លួន និងមិនស្តីបន្ទោសដល់កុមារឡើយ ទោះបីជាកុមារបបួល ឬ បញ្ចេញសកម្មភាពតាមរបៀបទាក់ទាញក៏ដោយ។

៣.៣.៤ ប្រសិនបើមានការល្មើសលើក្រមអាកប្បកិរិយា ដូចមានចែងខាងលើ នោះនឹងមានចំណាត់ការ ដូចជារាយការណ៍ទៅប៉ូលីស បញ្ឈប់ពីការងារ ដាក់វិន័យ។ល។ ស្របតាមគោលនយោបាយអង្គការអាយស៊ីស៊ី និងយោងតាមច្បាប់កម្ពុជា។

## ៣.៤ ការជ្រើសរើស និង សម្រាំងបុគ្គលិក

៣.៤.១ ការផ្ទៀងផ្ទាត់មើលលើបុគ្គលិកអាយស៊ីស៊ីដែលធ្វើការជាមួយកុមារ តម្រូវឱ្យធ្វើក្នុងកំឡុងពេលដំណើរការជ្រើសរើស និងសម្រាំងបុគ្គលិក។

៣.៤.២ គោលនយោបាយការការពារកុមារអាយស៊ីស៊ី ត្រូវបានភ្ជាប់ជាមួយនឹងកិច្ចសន្យាការងារអាយស៊ីស៊ី។ នេះមានន័យថា នៅពេលបុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី ចុះហត្ថលេខាលើកិច្ចសន្យាការងារ នោះពួកគាត់ក៏យល់ព្រមអនុវត្តតាមអ្វីដែលមានចែងក្នុងគោលនយោបាយការការពារកុមារ និងគោលនយោបាយបុគ្គលិកជាតិអាយស៊ីស៊ី(សម្រាប់បុគ្គលិកជាតិ និងអ្នកស្ម័គ្រចិត្ត) / គោលនយោបាយបុគ្គលិកបរទេស(សម្រាប់បុគ្គលិកបរទេស)។ គោលនយោបាយការការពារកុមារអាយស៊ីស៊ី ត្រូវតែបានអាន និងចុះហត្ថលេខា មុននឹងចាប់ផ្តើមធ្វើការជាមួយអង្គការអាយស៊ីស៊ី។

៣.៤.៣ អង្គការអាយស៊ីស៊ី នឹងផ្តល់ការងារឱ្យយុវជនពេញវ័យតែប៉ុណ្ណោះ ឬទទួលពួកគេ ជាអ្នកស្ម័គ្រចិត្ត/អ្នកហាត់ការ ស្របតាមច្បាប់ការងាររបស់រាជរដ្ឋាភិបាលកម្ពុជា៖
- កុមារក្រោមអាយុ ១៥ឆ្នាំ នឹងមិនមានសិទ្ធិទទួលបានប្រាក់ឈ្នួលការងារទេ។
- កុមារក្រោមអាយុ ១៨ឆ្នាំ មិនអាចចុះហត្ថលេខាកិច្ចសន្យាការងារដោយគ្មានការយល់ព្រមពីឪពុកម្តាយឬអ្នកមើលថែឡើយ។
- កុមារ មិនត្រូវធ្វើការពេលយប់ទេ។
- កុមារមានអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ អាចធ្វើកិច្ចការណាដែលស្រាលៗប៉ុណ្ណោះ៖
    - មិនបណ្តាលឱ្យបង្កគ្រោះថ្នាក់ដល់សុខភាពរបស់ពួកគេ ឬដល់ការអភិវឌ្ឍផ្នែករាងកាយ និងស្មារតីឡើយ។

- មិនរារាំងពួកគេក្នុងការទៅសាលារៀន ឬចូលរួមកម្មវិធីបណ្តុះបណ្តាលទេ។

## ៣.៥ ការឆ្លើយតបចំពោះការចោទប្រកាន់

៣.៥.១ រាល់គ្រប់លំដាប់ថ្នាក់បុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី អាចលើកយកកត្តាសក្តានុពលនៃការរំលោភបំពានមកពិភាក្សានៅក្នុងអង្គការ។

៣.៥.២ រាល់គ្រប់លំដាប់ថ្នាក់បុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី នឹងមិនប្រឈមនឹងការដាក់ទោសឡើយ ប្រសិនបើពួកគេមានការសង្ស័យ ឬ ចោទប្រកាន់ទាស់នឹងបុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ីដទៃ។

៣.៥.៣ នៅពេលមានការចោទប្រកាន់ចំពោះបុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី ថាបានរំលោភបំពានលើកុមារ នោះអង្គការអាយស៊ីស៊ី នឹងចាត់វិធានការសមស្រប ដើម្បីដោះស្រាយស្ថានការណ៍។

៣.៥.៤ ជាបឋម ប្រធានគម្រោងនឹងផ្តល់ព័ត៌មានជូនដល់បុគ្គលិកទទួលការចាត់តាំង/នាយកប្រតិបត្តិ។ ប្រសិនបើនាយកប្រតិបត្តិជាកម្មវត្ថុនៃចោទប្រកាន់ នោះត្រូវផ្តល់ព័ត៌មានដល់ប្រធានក្រុមប្រឹក្សាភិបាលវិញ។ បុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី អាចផ្តល់ព័ត៌មានដល់ប្រធានរបស់ពួកគេ ប៉ុន្តែក៏អាចផ្តល់ព័ត៌មានដល់នាយកប្រតិបត្តិតែម្តងក៏បាន។ (**សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធ ២**)

៣.៥.៥ ការចោទប្រកាន់ នឹងត្រូវរក្សាជារឿងសម្ងាត់ ក្រៅពីអ្នកមានសមត្ថកិច្ចក្នុងក្រុមការការពារកុមារអាយស៊ីស៊ី។ អង្គការអាយស៊ីស៊ី/អង្គការលើកាដូ ក៏អាចតម្រូវឱ្យបង្ហាញព័ត៌មានដល់នាយកប្រតិបត្តិឬប្រធានក្រុមប្រឹក្សាភិបាល។ (**សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធ ២**)

## ៣.៦ ការប្រាស្រ័យទាក់ទង

៣.៦.១ ការប្រាស្រ័យទាក់ទងរបស់អង្គការអាយស៊ីស៊ី អំពីកុមារ នឹងឆ្លុះបញ្ចាំងរូបភាពដែលសមរម្យ និងផ្តល់ការគោរព គឺមិនប្រើប្រាស់ស្ថានភាពរបស់ពួកគេ ដើម្បីធ្វើអាជីវកម្ម(កេងប្រវ័ញ្ច)ឡើយ។

៣.៦.២ អង្គការអាយស៊ីស៊ី នឹងប្រើប្រាស់កុំព្យូទ័រ ទូរស័ព្ទដៃ ម៉ាស៊ីនថតវីដេអូ ម៉ាស៊ីនថតរូបភាព ឬប្រព័ន្ធសង្គមឱ្យបានត្រឹមត្រូវ និងមិនធ្វើអាជីវកម្ម ឬមិនយាយីរំខានកុមារ ឬមិនចូលឆែកមើល(ប្រើប្រាស់)សម្ភារៈដែលកេងប្រវ័ញ្ចលើកុមារ (រូបភាព និង វីដេអូ) តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយឡើយ។

៣.៦.៣ អង្គការអាយស៊ីស៊ី នឹងមិនដាក់បង្ហាញរូបភាពកុមារក្នុងស្ថានភាពងាយរងគ្រោះឡើយ (ដូចជា កុមារគ្មានស្លៀកសម្លៀកបំពាក់ ពលកម្មកុមារ)។

៣.៦.៤ អង្គការអាយស៊ីស៊ី នឹងយកចិត្តទុកដាក់ជាពិសេស ដោយការពារអត្តសញ្ញាណរបស់កុមារ និងការពារទីតាំងភូមិសាស្ត្រជាក់លាក់របស់ពួកគេក្នុងសម្ភារៈទំនាក់ទំនងទូទៅឡើយ។

៣.៦.៥ មុននឹងថតរូប ឬប្រើរូបភាពរបស់កុមារ ដាក់លើគេហទំព័រ ឬសម្ភារៈបោះពុម្ពផ្សាយ ត្រូវទទួលការយល់ព្រមនិងការអនុញ្ញាត ពីបុគ្គលិកបង្គោលរបស់អង្គការអាយស៊ីស៊ី កុមារ មាតាបិតា ឬអ្នកមើលថែរបស់កុមារជាមុនសិន។ (**សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធ ៦**)

## ៣.៧ ការលើកកម្ពស់ការយល់ដឹង និង ការបណ្តុះបណ្តាល

៣.៧.១ អង្គការអាយស៊ីស៊ី មានកាតព្វកិច្ចលើកកម្ពស់ការយល់ដឹង ដល់បុគ្គលិក/អ្នកពាក់ព័ន្ធរបស់អង្គការអាយស៊ីស៊ី អំពីការការពារកុមារ និងគោលនយោបាយការការពារកុមារ។ ប្រធាន នឹងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលអំពីការការពារកុមារ ដល់ក្រុមសមាជិកនិងបុគ្គលិកថ្មី។ ក្រុមនាយកប្រតិបត្តិនឹងទទួលខុសត្រូវក្នុងបណ្តុះបណ្តាល និង ត្រួតពិនិត្យឡើងវិញអំពីការការពារកុមារដល់ប្រធាន។

៣.៧.២ រាល់គ្រប់លំដាប់ថ្នាកបុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី គួរទទួលបានឱកាសរៀនអំពីរបៀបការការពារកុមារពីគ្រោះថ្នាក់ របៀបស្គាល់យល់ និងឆ្លើយតបចំពោះរាល់កង្វល់នានាទាក់ទងនឹងការរំលោភបំពានលើកុមារ។

៣.៧.៣ ខិត្តប័ណ្ណសមស្រប ដូចជាទូរស័ព្ទជំនួយបន្ទាន់ និងរបៀបរាយការណ៍ឧបទ្ទវហេតុ និងព័ត៌មានពីសុវត្ថិភាពកុមារ នឹងត្រូវបានតាំងបង្ហាញជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់រាល់គ្រប់លំដាប់ថ្នាកបុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី។

៣.៧.៤ គោលនយោបាយការការពារអង្គការអាយស៊ីស៊ី នឹងត្រូវបានដាក់លើគេហទំព័ររបស់អង្គការអាយស៊ីស៊ី ដើម្បីបង្ហាញជាសាធារណៈ ពីការប្តេជ្ញាចិត្តក្នុងការការពារកុមារ។

## ៣.៨ ការអនុវត្តគោលនយោបាយការពារកុមារ

៣.៨.១ រាល់គ្រប់លំដាប់ថ្នាក់បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី នឹងទទួលបានគោលនយោបាយការការពារកុមារមួយច្បាប់ជាភាសាអង់គ្លេស និង/ឬ ភាសាខ្មែរ។

៣.៨.២ អង្គការអាយស៊ីស៊ី នឹងធ្វើឱ្យប្រាកដថា លេខទូរស័ព្ទត្រូវបានតាំងបង្ហាញឱ្យច្បាស់ៗក្នុងអង្គការ ដើម្បីបង្កភាពងាយស្រួលដល់មនុស្សគ្រប់គ្នា។ (**សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធ ៥**)

៣.៨.៣ ទម្រង់របាយការណ៍ នឹងរក្សាទុកក្នុងលក្ខណៈដែលបង្កភាពងាយស្រួលដល់បុគ្គលិកទាំងអស់ យកបាន ដើម្បីធ្វើការរាយការណ៍ ក្នុងករណីមានការបំពានលើក្រមដែលបានចែង។ (**សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធ ៣**)

៣.៨.៤ បុគ្គលិកម្នាក់ៗត្រូវតែចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ដែលបញ្ជាក់ថា ពួកគេបានអាន និង យល់ព្រមគោរពតាមគោលនយោបាយ និងដឹងថានឹងត្រូវមានចំណាត់ការ ប្រសិនបើមានអាកប្បកិរិយាមិនសមរម្យណាមួយកើតឡើង។

៣.៨.៥ ទីតាំង ដូចជាសាលារៀន ដែលការងាររបស់អង្គការអាយស៊ីស៊ីពាក់ព័ន្ធនឹងកុមារ នឹងត្រូវជូនដំណឹងអំពីក្រមច្បាប់និងក្រមសីលធម៌ តាមលទ្ធភាពដែលអាចធ្វើទៅបាន។

## ៣.៩ ការត្រួតពិនិត្យតាមដាន និង វាយតម្លៃ

ថ្នាក់ដឹកនាំ និងប្រធានអាយស៊ីស៊ី ប្តេជ្ញាចិត្តតាមដានអាកប្បកិរិយារបស់បុគ្គលិក និង សកម្មភាពផ្សេងៗទៀតជាទៀងទាត់និងជាប្រចាំ ដើម្បីធានាការការពារដល់កុមារ ឱ្យបាននៅក្នុងកម្រិតខ្ពស់បំផុតតាមលទ្ធភាពអាចធ្វើបាន។ ការនេះអាចសម្រេចបានតាមរយៈ

៣.៩.១ បុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី យល់ដឹងថាកិរិយាមាយាទរបស់ពួកកាត់ នឹងត្រូវត្រួតពិនិត្យតាមដាន និងរម្លឹកឡើងវិញយ៉ាងទៀងទាត់ស្របតាមគោលនយោបាយការការពារកុមារ និងនីតិវិធីអាយស៊ីស៊ី។

៣.៩.២ រក្សានូវការប្រាស្រ័យទាក់ទងល្អរវាងរាល់គ្រប់លំដាប់ថ្នាក់បុគ្គលិក/អ្នកពាក់ព័ន្ធអាយស៊ីស៊ី ដើម្បីលើកទឹកចិត្តឱ្យពួកគាត់រាយការណ៍រាល់កង្វល់ ឧបទ្ទវហេតុ ឬការប្រព្រឹត្តពុំត្រឹមត្រូវទាក់ទងនឹងការការពារ និងសុវត្ថិភាពកុមារ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាព។

៣.៩.៣ ក្នុងករណីឧបទ្ទវហេតុនៃការប្រព្រឹត្តពុំត្រឹមត្រូវ នោះអង្គការអាយស៊ីស៊ីនឹងធ្វើការវាយតម្លៃ និង ប៉ាន់ប្រមាណឡើងវិញជាបន្ទាន់រាល់គ្រប់លំដាប់ថ្នាក់ ដើម្បីធ្វើការកែសម្រួល និងបន្ថែមការការពារ តាមភាពចាំបាច់ជាក់ស្តែង។

៣.៩.៤ អង្គការអាយស៊ីស៊ី នឹងធ្វើឱ្យប្រាកដថាគោលនយោបាយការការពារកុមារ យកមកប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពក្នុងគ្រប់កាលៈទេសៈដែលពាក់ព័ន្ធ។ អង្គការអាយស៊ីស៊ី នឹងបន្តត្រួតពិនិត្យតាមដានហានិភ័យទាំងឡាយ( ឧទាហរណ៍ ការរៀបចំគម្រោង និងអនុត្តន៍គម្រោង ) ដែលទាក់ទិនទៅនឹងកុមារ និងធ្វើការផ្លាស់ប្តូរ គោលនយោបាយការការពារកុមារក្នុងករណីចាំបាច់យ៉ាងហោចណាស់ ៣ឆ្នាំម្តង។

## ៣.១០ សេចក្តីថ្លែងការណ៍អំពីការប្តេជ្ញាចិត្ត

រាល់គ្រប់លំដាប់ថ្នាក់បុគ្គលិក/ភាគីពាក់ព័ន្ធអាយស៊ីស៊ី និងជនទាំងឡាយណាមានទំនាក់ទំនងនឹងការងារអង្គការអាយស៊ីស៊ី ត្រូវចុះហត្ថលេខា និងអះអាងបញ្ជាក់ថា ពួកគាត់បានអាន និងបានយល់ពីគោលនយោបាយការការពារកុមារអាយស៊ីស៊ី ព្រមទាំងយល់ព្រមអនុវត្តតាមគោលនយោបាយការការពារកុមារអាយស៊ីស៊ី។

ច្បាប់ចម្លង១ច្បាប់ នឹងត្រូវរក្សាទុកនៅការិយាល័យកណ្តាលរបស់អង្គការអោយស៊ីស៊ី ឬក្នុងការិយាល័យគម្រោង។ បុគ្គលិក/ភាគីពាក់ព័ន្ធអោយស៊ីស៊ី នឹងចុះហត្ថលេខាលើកិច្ចសន្យាការងារ និងត្រូវយល់ព្រមអនុវត្តតាមគោលនយោបាយការការពារកុមារអង្គការអោយស៊ីស៊ី។

**ខ្ញុំបាទ/នាងខ្ញុំឈ្មោះ______________________________សូមអះអាងបញ្ជាក់ថា៖**

១. ខ្ញុំបានអាន បានយល់ និងអនុវត្តតាមគោលនយោបាយការការពារកុមារអោយស៊ីស៊ី។

២. ខ្ញុំនឹងធ្វើតាមនិតិវិធី ដែលបានចែងក្នុងគោលនយោបាយការការពារកុមារអង្គការអោយស៊ីស៊ី។

៣. ខ្ញុំមិនធ្លាប់ជាប់ទោសចំពោះបទល្មើសផ្សេងៗទាក់ទងនឹងការរំលោភបំពាន ឬការធ្វើអាជីវកម្មលើកុមារឡើយ។

៤. ខ្ញុំយល់ថា ប្រសិនបើមានគេប្តឹងទាស់នឹងខ្ញុំទាក់ទងទៅនឹងការរំលោភបំពានលើកុមារ ក្នុងខណៈពេលដែលខ្ញុំកំពុងធ្វើការពាក់ព័ន្ធ ក្នុងសកម្មភាពរបស់អង្គការអោយស៊ីស៊ី នោះការចោទប្រកាន់នឹងត្រូវបានគេធ្វើការស៊ើបអង្កេតយ៉ាងម៉ត់ចត់ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរសមត្ថកិច្ចដែលសមស្រប។

ហត្ថលេខា ______________________________________

កាលបរិច្ឆេទ______________________________________

# សទ្ទានុក្រម

| | | |
|---|---|---|
| មនុស្សពេញវ័យ | - | ជាជនទាំងឡាយដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅដូចដែលមានចែងក្នុងរដ្ឋធមនុញ្ញកម្ពុជា។ |
| កុមារ | - | ជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ ដូចដែលមានចែងក្នុងរដ្ឋធមនុញ្ញកម្ពុជា។ |
| អ្នកជាប់កិច្ចសន្យា | - | ជាជនទាំងឡាយណាដែលបានជួលដោយអង្គការអាយសុីសុី (ទាំងជនជាតិខ្មែរ ឬបរទេស) ធ្វើការដើម្បីប្រាក់ឈ្នួល។ |
| បុគ្គលិកបរទេស | - | ជាជនទាំងឡាយណាដែលត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដោយភ្នាក់ងារសមាជិកដៃគូគាំទ្រ ឬជនដែលបានជួលដូចជនជាតិខ្មែរ ដើម្បីបម្រើការក្នុងកំឡុងពេលកិច្ចសន្យាជាមួយអង្គការអាយសុីសុី។ |
| អង្គការលើកាដូ | - | ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩២ ដើម្បីការពារសិទ្ធិមនុស្ស និងសិទ្ធិកុមារ ក្នុងប្រទេសកម្ពុជា និងជួយលើកកម្ពស់ការគោរពដល់សិទ្ធិសុីវិល និង សិទ្ធិនយោបាយដោយរដ្ឋាភិបាលកម្ពុជា និង ស្ថាប័ននានា។ |
| បុគ្គលិកជាតិ | - | ជាប្រជាជនកម្ពុជាដែលត្រូវបានគេជ្រើសរើសយ៉ាងត្រឹមត្រូវ ដោយអង្គការអាយសុីសុី ដើម្បីធ្វើការឱ្យអង្គការក្នុងកំឡុងពេលនៃកិច្ចសន្យា។ |
| អ្នកស្ម័គ្រចិត្ត | - | ជាជនទាំងឡាយណាដែលត្រូវបានជ្រើសរើសដ៏ត្រឹមត្រូវដោយភ្នាក់ងារសមាជិក ដៃគូគាំទ្រ ឬអង្គការអាយសុីសុី ដោយផ្ទាល់ក្នុងតួនាទីរយៈពេលខ្លីណាមួយសម្រាប់ធ្វើការឱ្យអង្គការអាយសុីសុី។ |
| ភ្ញៀវ | - | ជាជនទាំងឡាយណាដែលចុះមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ដែលបានអនុម័តដោយនាយកប្រតិបត្តិ ជាភ្ញៀវផ្លូការអាយសុីសុី។ ប្រសិនណា ភ្ញៀវមិនមានទំនាក់ទំនងជាមួយកុមារ ក្នុងកំឡុងពេលចុះទស្សនកិច្ចអង្គការអាយសុីសុីទេ នោះមិនចាំបាច់ត្រូវចុះហត្ថលេខាលើគោលនយោបាយការការពារកុមារឡើយ។ |